USAID | CAMBODIA
FROM THE AMERICAN PEOPLE

សេចក្តីប្រកាសព័ត៌មាន ថ្ងៃទី០៦ ខែតុលា ឆ្នាំ២០០៥

# ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) បានចុះហត្ថលេខាថ្មីមួយជាមួយ Nathan-MSI Group ដើម្បីអនុវត្តគំរោងធ្វើឱ្យប្រសើរឡើងនូវលក្ខណៈប្រកួតប្រជែង និង ផលិតភាពពលកម្ម ក្នុងឧស្សាហ៍កម្មកាត់ដេរនៅកម្ពុជា

នៅថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ២០០៥ ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៏អន្តរជាតិ (USAID) បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងថ្មីមួយជាមួយ Nathan-MSI Group ក្នុងការអនុវត្តគំរោងរយៈពេល៣ឆ្នាំ ដែលមានចំនួនថវិកាសរុប ៣,៥ លានដុល្លារសហរដ្ឋអាមេរិក ដើម្បីធ្វើឱ្យប្រសើរឡើងនូវលក្ខណៈប្រកួតប្រជែង និង ផលិតភាពពលកម្មក្នុងឧស្សាហ៏កម្មកាត់ដេរនៅកម្ពុជា ។

ភ្នំពេញ (ថ្ងៃទី ២៣ ខែកញ្ញា) ថ្ងៃនេះរដ្ឋាភិបាលសហរដ្ឋអាមេរិកក៏បានចុះហត្ថលេខាជាមួយទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៏អន្តរជាតិផងដែរ ផ្តល់នូវថវិការជិត ៣,៥ លានដុល្លារ ដែលជាមូលនិធិសំរាប់ ធ្វើឱ្យប្រសើរឡើងនូវលក្ខណៈប្រកួតប្រជែង និង ផលិតភាពពលកម្មក្នុងឧស្សាហ៏កម្មកាត់ដេរនៅកម្ពុជា ។

កិច្ចព្រមព្រៀងនេះបានផ្តល់ជាមូលនិធិចំនួន ១.៧៥ លានដុល្លារ ដើម្បីជាមធ្យោបាយធ្វើអោយវិស័យផលិតកម្មកាត់ដេរបានប្រសើឡើង ប្រកបដោយលក្ខណៈប្រកួតប្រជែងខ្ពស់ ទាំងក្នុងតំបន់អាស៊ីអាគ្នេយ៏ និងតំបន់ដទៃទៀតក្នុងពិភពលោក ។ មូលនិធិនេះ នឹងត្រូវបានប្រើប្រាស់សំរាប់ជំរុញអោយមានសកម្មភាពផ្សេងៗ ដែលពាក់ព័ន្ធនឹងការហ្វឹកហ្វឺនថ្នាក់គ្រប់គ្រង និងកម្មករ នៅក្នុងវិស័យសំខាន់ៗនៃប្រព័ន្ធផលិតកម្ម ។ កម្មវិធីទាំងឡាយនឹងត្រូវអនុវត្តតាមរយៈសហគ្រិនម៉ៅការចំបងម្នាក់ និងអង្គការកម្ពុជា ដែលធ្វើការសំរបសំរួលយ៉ាងជិតស្និទ្ធជាមួយផលិតករកាត់ដេរក៏ដូចជាទីភ្នាក់ ងារដទៃទៀត ។

គោលបំណងរបស់គំរោង USAID នេះគឺដើម្បីកែលំអស្ថានភាពប្រកួតប្រជែងឧស្សាហកម្មកាត់ដេរក្នុងប្រទេសកម្ពុជា ដោយបង្កើតអោយមាន មជ្ឈមណ្ឌលហ្វឹកហ្វឺនផលិតភាពឧស្សាហកម្មកាត់ដេរ ដែលនឹងត្រូវអភិវឌ្ឍន៍យុទ្ធសាស្ត្រប្រកួតប្រជែង និងអនុវត្តផែនការសំរាប់កម្មវិធីហ្វឹកហ្វឺនតាមមូលដ្ឋាន និងប្រព័ន្ធគ្រប់គ្រងដែលទទួលបានជោគជ័យ ។ ការប្រតិបត្តិយុទ្ធសាស្ត្រទាំងនេះរយៈពេលជាងបីឆ្នាំនឹងដើរតួនាទីជាផែនការជាក់ស្តែងទាំងពីរដើម្បីពង្រីកឥទ្ធិពលសេដ្ឋកិច្ចតាមរយៈសេដ្ឋកិច្ចនៃវិស័យកាត់ដេរ ។

ការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោករបស់កម្ពុជា ជាកំលាំងដើម្បីចាប់ផ្តើម ការអនុវត្តន៏ដែលទទួលបានជោគជ័យតាមខ្នាតអន្តរជាតិ តាមរយៈគោលនយោបាយជាក់លាក់ដែលថែងថា មានអភិបាលកិច្ច និងការទាក់ទងផ្នែកច្បាប់ ។ ការងារទាក់ទិននឹងឧស្សាហកម្មកាត់ដេរ ដែលរួមមានតុលាការពលកម្ម និងលិខិតបញ្ជាក់បទដ្ឋានការងារនឹងត្រូវផ្តល់មូលនិធិក្នុងពេលជាមួយគ្នា ដោយ USAID នាពេលនេះ បានទទួលការពិចារណាយ៉ាងល្អិតល្អន់ដើម្បីផ្តល់ផលប្រយោជន៏ដល់ឧស្សាហកម្មកាត់ដេរ ដែលជាប្រភពនៃទីផ្សារការងារ ការលូតលាស់សេដ្ឋកិច្ច និងរូបិយប័ណ្ណ ។ ជាការពិតណាស់ ដើម្បីជាពន្លឺដល់គំរោងនេះ ឧស្សាហកម្មកាត់ដេរមួយដែលកាន់តែមានផលិតភាព និងលក្ខណៈប្រកួតប្រជែង (ឧស្សាហកម្មដែលនាំចេញធំជាងគេរបស់កម្ពុជា ) នឹងកាន់តែមានឥទ្ធិពល ជាងកម្មកររាប់លាននាក់ក្នុងឧស្សាហកម្មមួយដែលជួយដល់សេដ្ឋកិច្ចកម្ពុជាទាំងមូលរហូតដល់ទៅ 40% ។

គំរោងបីឆ្នាំត្រូវអនុវត្តក្នុងប្រទេសកម្ពុជានេះ គ្រោងនឹងចាប់ផ្តើមក្នុង ខែតុលា ឆ្នាំ ២០០៥ នេះ ។